# សេចក្តីប្រកាសជំរាបឪពុកឬម្តាយម្ខាងទៀត

| ខណ្ឌ | |
|---|---|
| ឈ្មោះសំណុំរឿង | |
| លេខសំណុំរឿង | លេខសំគាល់ខ្លួន |
| ឈ្មោះអ្នកកាន់សំណុំរឿង | |

មានសំណួរឬ? សូមសួរអ្នកកាន់សំណុំរឿងរបស់លោកអ្នក ។

(ADDRESSEE)

កាលបរិច្ឆេទសេចក្តីប្រកាស : ____________________

សេចក្តីប្រកាសនេះ គឺជំរាបលោកអ្នកឱ្យដឹងថាឈ្មោះ ______________________________ មានបញ្ហាមួយនៅក្នុងការចូលរួមជាមួយកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ (Welfare to Work) ។ យើងចង់ធ្វើការដោះស្រាយដោយបង្កើតជាគំរោងការមួយដើម្បីបំពេញទៅតាមការតម្រូវនៃកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ ។ បើសិនជាលោកអ្នកយល់ស្របជាមួយនឹងគំរោងការនេះ ប្រាក់ជំនួយនៃគ្រួសាររបស់លោកអ្នកនឹងមិនត្រូវបានបន្ថយឡើយ ។ ប៉ុន្តែបើសិនជាបញ្ហានេះមិនអាចដោះស្រាយបានទេ លោកអ្នកហើយនិង ____________________ ____________________ទាំងពីរនាក់ អាចបាត់បង់ប្រាក់ជំនួយ ។ កូនរបស់លោកអ្នកនឹងនៅតែទទួលចំណែកនៃប្រាក់ជំនួយរបស់គេ ។

លោកអ្នកនឹងនៅតែទទួលចំណែកនៃប្រាក់ជំនួយរបស់លោកអ្នក បើសិនជាលោកអ្នកបាននៅក្នុងកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការរួចហើយ ឬលោកអ្នកយល់ព្រមចូលរួមជាមួយកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ ។ លោកអ្នកអាចយល់ព្រមចូលរួមជាមួយកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការនៅពេលណាក៏បាន ។ ប៉ុន្តែបើសិនជាលោកអ្នកយល់ព្រមចូលរួមនៅក្រោយពេលដែលគេបញ្ឈប់ប្រាក់ជំនួយ លោកអ្នកត្រូវតែស្នើសុំប្រាក់ជំនួយឡើងវិញ ។

លោកអ្នកអាចមិនបាច់ចូលរួមជាមួយកម្មវិធីជួយឱ្យចេញពីជំនួយសុខុមាលភាពទៅធ្វើការ បើសិនជាលោកអ្នកមានមូលហេតុត្រឹមត្រូវមួយ ។ មូលហេតុត្រឹមត្រូវខ្លះសំរាប់ការមិនចូលរួមមាន : លោកអ្នកគឺជាជនរងគ្រោះនៃការធ្វើបាបក្នុងគ្រួសារ ហើយការចូលរួមអាចនាំឱ្យមានទុក្ខទោសទៅដល់លោកអ្នកនិងគ្រួសារ ឬលោកអ្នកមិនមានកិច្ចថែរក្សាក្មេង យានជំនិះ ឬការចំណាយទាក់ទងទៅនឹងការងារដែលបានត្រូវការដើម្បីចូលរួម ។

សូមទូរស័ព្ទ ______________________________ សំរាប់ពត៌មានបន្ថែម ។